**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ២០៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល។

PheakdeyLaw Book Store

## សម្រេច

**មាត្រា១ៈ**

ត្រូវបានកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព លើផ្ទៃដីសរុបចំនួន **៩.២៣៧(ប្រាំបួនពាន់ ពីររយ សាមសិប ប្រាំពីរ)ហិកតា** ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តព្រះវិហារ សម្រាប់ផ្តល់ជូនក្រុមហ៊ុន **ខេមបូឌា ដោន ផ្លេនថេសិន អិលធីឌី** (Cambodia Dawn Plantation Ltd) ធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដំណាំកសិ-ឧស្សាហកម្ម ដែលមានទីតាំង និងនិយាមកា ដូចមានក្នុងផែនទីភ្ជាប់នឹងលិខិតលេខ ៩៩៧ សជណ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០១១ ជាឧបសម្ព័ន្ធ។

www.pheakdeylaw.com

**មាត្រា២៖**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣៖**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

គណៈរដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*__កន្លែងទទួល:__*

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី "__ដើម្បីគោរពជូនជ្រាប__"
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

បណ្ណាគារ ភក្តីឡង់
PheakdeyLaw Book Store

ផែនទី ទីតាំងដីវិនិយោគអភិវឌ្ឍន៍លើវិស័យកសិ-ឧស្សាហកម្ម និងដំណាំកៅស៊ូ របស់ក្រុមហ៊ុន ខេមបូឌា ដោន ផ្លេនថេសិន លីមីធីត
( Cambodia Dawn Plantation Ltd.) ស្ថិតនៅក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ លើផ្ទៃដី ៩២៣៧ ហិកតា




N
W E
S

មាត្រដ្ឋាន 1:90,000

0 1 2 Kilometers

Map Information
Projection: Indian 1960, UTM Zone 48N
Datum: Indian 1960
Map Units: Meters

| Id | N | X | Y |
|---|---|---|---|
| 1 | A | 499063 | 1547548 |
| 2 | B | 498485 | 1552801 |
| 3 | C | 495867 | 1553222 |
| 4 | D | 492870 | 1556265 |
| 5 | E | 490080 | 1560135 |
| 6 | F | 487603 | 1564880 |
| 7 | G | 482922 | 1564475 |
| 8 | H | 488611 | 1555450 |
| 9 | I | 493590 | 1547550 |

**សញ្ញាសំគាល់**

- ចំណុចនិយាមកា
- ទីតាំងដីវិនិយោគ
- ផ្លូវជាតិ
- ផ្លូវលំ
- ស្ទឹង, អូរ
- ព្រំប្រទល់ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព

ផែនទី និងនិយាមកានេះ ជាឯកសារ
ភ្ជាប់នឹងលិខិតលេខ ...៥.៥.៧... សជណ
ចុះថ្ងៃទី ... ខែ ... ឆ្នាំ ២០១១
ទេសរដ្ឋមន្ត្រី ប្រធានអង្គភាពគណៈរដ្ឋមន្ត្រី

ផែនទី និងនិយាមកានេះ ជាឯកសារ
ភ្ជាប់នឹងលិខិតលេខ ១១០៤ ...
ចុះថ្ងៃទី ...១០... ខែ ...សីហា... ឆ្នាំ ២០១១
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន
...